# ដើមត្នោត

ពេលខ្ញុំចាស់ទុំជាផ្លែ    អ្នកស្រុកពុកម៉ែកែជាចំណី ។
ផ្អែតហើយបោះខ្ញុំទៅដី    ខ្ញុំខំឃ្នាតខ្ចីដុះសារឡើងវិញ ។
ស្លឹកមួយត្រួយមានក្រពេញ    មនុស្សម្នាររមិញជីកគាស់កកាយ ។
គាស់ខ្ញុំមកស្ងោរដូចបាយ    បានផ្អែតឡើយណាយសប្បាយរាំច្រៀង ។
ខ្ញុំធំស្រលះរូបរាង    អ្នកមកកាប់ធាងកាត់ធ្វើជាផ្លិត ។
ខ្ញុំខ្ពស់មានម្លប់បាំងបិទ    អ្នកជៀលអ្នកចិតកខ្ញុំយកគាវ ។
ខ្ញុំខ្ពស់ធំហួសពីស្មាវ    អ្នកយកឡៀវអាកយកគម ។
អោយខ្ញុំយំឈឺមិនព្រម    អ្នកឃើញមានគមអ្នកចង់កកូរ ។
មិនដឹងថាខ្ញុំឈឺថ្ងូរ    អ្នកឆ្វាញ់កកូរខ្ញុំស្លាប់រូបា ។
បើសិនជាខ្ញុំធំកាលណា    ខ្ញុំខំចេញផ្កាអោយអ្នកធ្វើស្ករ ។
ចេញផ្លែអោយអ្នកបរបរ    ចេញត្រួយបន្តអោយធ្វើកន្តំ ។
ស្លឹកចាស់ខ្ញុំខំសន្សំ    អ្នកកាត់បង្ខំយកទៅប្រក់ផ្ទះ ។
ខ្ញុំឃាត់ការពារមិនឈ្នះ    អ្នកបានដេកផ្ទះឯខ្ញុំឈាមហូរ ។
មិនដែលរអ៊ូឬថ្ងូរ    គួអ្នកអាសូរដល់ដល់ពូចត្នោតផង ។
បើកាប់សូមស្តាប់បំណង    កុំកាប់ប្អូនបងខ្ញុំដែលក្មេងខ្ចី ។
ខ្ញុំតូចឆ្ងាញ់តែមាត់ឆី    កុំកាប់ខ្ញុំអីសុំរស់ដល់ចាស់ ។
ខ្ញុំផ្តាស់ចិញ្ចឹមលោកម្ចាស់    អោយផលច្រើនណាស់អ្នករស់គ្រប់ប្រាណ ។
ចង់រស់ដោយសុខសាន្ត    លោកម្ចាស់ក៏បានសុខទាំងអស់គ្នា ។

ស្រីសន្ធរ ២០០២

សូយ ឡូត